**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងរវាងនាយិកាក្រុមហ៊ុនភោជនីយដ្ឋានសុខៈរីវើនិងតំណាងកម្មករនិយោជិក ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០២១ វេលាម៉ោង ៩ និង ៣០នាទី នៅក្នុងក្រុមហ៊ុនភោជនីយដ្ឋានសុខៈរីវើមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនថា ដោយសារការរីករាលដាលនិងចម្លងនៃជំងឺរលាកសួតប្រភេទថ្មីCovid-19ដែលជាហេតុបណ្តាលអោយមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកហើយក៏ជាហេតុដែលធ្វើអោយក្រុមហ៊ុនទទួលរងការខាតបង់ មិនមានប្រាក់ចំណូលសំរាប់ទ្រទ្រង់ប្រតិបត្តិការណ៍បន្តទៀតបាន។

ហេតុដូចនេះក្រុមហ៊ុនបានសំរេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកទាំងអស់ ចំនួន៤៧នាក់(ស្រី១៨នាក់)រយៈពេល៦០ថ្ងៃដោយគិតចាប់ពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ រហូតដល់ទី១៧ ខែកក្កដា ឆ្នាំ២០២១នៅក្នុងកំឡុងពេលនៃការព្យួរនេះកម្មករនិយោជិកនឹងមិនទទួលបានអត្ថប្រយោជន៍អ្វីពីក្រុមហ៊ុនឡើយ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីនាថ្ងៃខែឆ្នាំដដែលដោយសារភាគីទាំងសងខាងមានការស្និទ្ធស្នាលនិងយោគយល់គ្នាក្រោមស្មារតីទទួលនិងសហការគ្នាយ៉ាងល្អ។

ថ្ងៃពុធ១កើតខែជេស្ឋ ឆ្នាំឆ្លូវត្រីស័កព.ស២៥៦៥
សៀមរាប ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១

ហត្ថលេខា និងត្រា នាយិកា

ព្រះរាជាណាចក្រកម្ពុជា
សហគ្រាសឯកបុគ្គល
ភោជនីយដ្ឋាន សុខៈ រីវើរ
SOKKHAK RIVER I
Restaurant
KINGDOM OF CAMBODIA

ជុំនគាប់

តំណាងកម្មករនិយោជិក





សៀមសម្បត្តិ គាន់សាន់ជីណា